# ABA Bank and Smart Axiata Introduce IPification, Seamless Authentication and Registration Solution for ABA Mobile Banking Users

**20 October 2021, HONG KONG/PHNOM PENH – ABA Bank and Smart Axiata continue to lead Cambodia's digitalization by introducing the secure and customer-friendly solution for users' identification and protection: IPification, a one-click registration, authentication and fraud-prevention system. ABA Bank will introduce the seamless IPification technology to the subscribers of Smart Axiata, Cambodia's leading telecommunications operator, soon followed by other operators in the country.**

IPification is a one-click mobile identity solution that enables end users to verify their phone number, register and log in within milliseconds. Developed with security, user experience and data privacy in mind, it will allow ABA Bank to enhance the user experience on its mobile banking app and will be used instead of the SMS-based, one-time-password (OTP) system currently in place in the app activation process.

Having received numerous awards for its excellence over the last decade from financial magazines such as *The Banker*, *Global Finance* and *Euromoney*, ABA Bank has grown to become one of the top commercial banks and digital banking leaders in Cambodia, offering an entire spectrum of services to individuals, microbusinesses and SMEs. To further improve their advanced mobile banking solution, ABA is integrating IPification for frictionless user registration and authentication.

"We are excited to expand our strategic partnership with Smart Axiata and become the first Cambodian bank to introduce IPification on our mobile banking app. The security and convenience of mobile banking is our top priority, and the introduction of IPification will allow us to provide ABA Mobile users with an easier authentication process, keeping the app secure at the same time. The Bank will continue bringing the latest developments to the local market, further accelerating the digital transformation throughout the country," said Askhat Azhikhanov, ABA CEO.

Benefit Vantage Limited, the company behind IPification, is the leading global provider of mobile IP address-based authentication solutions.

"It's a privilege to work with two of the top digital leaders in Cambodia, ABA – the digital banking leader, and Smart Axiata, the leading mobile telecommunications operator. ABA will serve as a great example of what it means to put the users first by providing them with an

authentication solution that doesn't compromise security, user experience or data privacy," added Stefan Kostic, IPification CEO.

Smart Axiata subscribers who are ABA Mobile users will be the first to experience the seamless mobile authentication solution, IPification, for their mobile banking needs starting from mid-October 2021.

"Introducing the latest technologies and solutions to benefit users, both consumers and businesses, has always been a primary objective of Smart Axiata. Our partnership with Benefit Vantage Limited is yet another example of the role mobile operators play as key enabler in developing the economy and technology landscape in the Kingdom. We are glad that our strategic partner ABA is the first to provide the solution and are looking forward to many other businesses taking steps towards greater security and convenience for users," said Thomas Hundt, Smart Axiata CEO.

**About IPification**
IPification is building the backbone for mobile authentication of today and tomorrow. By verifying the device, SIM & phone number via IP address, IPification patented technology is enabling secure, passwordless, zero-tap compatible mobile user authentication, registration, transaction approval and fraud prevention solutions for any mobile application. Readily available across numerous countries and regions, IPification is trusted by some of the leading telco, technology, payment, and OTT companies including Microsoft, GBG, DataZoo, 3HongKong, Axiata Digital.

Benefit Vantage Limited is a provider of security and data backup solutions in Asia, headquartered in Hong Kong, it has a subsidiary in Switzerland, IPIFICATION INTERNATIONAL AG, and representatives operating in the U.S., U.K., Serbia, Russia, Bosnia, Brazil, India, Vietnam and Pakistan.

For more information, please visit www.ipification.com

**Media Inquiry:**
IPification
Alexandra Kalinina
alexandra.kalinina@ipification.com

**About ABA Bank**
ABA Bank is Cambodia's leading financial institution. With 79 branches, 600+ self-banking machines across the country, and advanced self-banking and mobile banking platforms, ABA

Bank reaches out to a large number of customers with an array of modern financial services. For more info visit www.ababank.com.

ABA is a subsidiary of National Bank of Canada, a financial institution with around US$274 billion as of April 30, 2021. Headquartered in Montreal, it has branches in almost every Canadian province with 2.7 million personal clients. It is the sixth largest bank in Canada and the leading bank in Quebec where it is the partner of choice among SMEs.
For more info visit www.nbc.ca.

**Media Inquiry:**
ABA Bank
Chiva Chan
Chan.Chiva@ababank.com

**About Smart**
Smart Axiata Co., Ltd., Cambodia's leading mobile telecommunications operator, currently serves 8 million subscribers under the 'Smart' brand. Smart Axiata is part of Axiata Group Berhad, one of Asia's largest telecommunications groups.

Smart is at the forefront of mobile technology advancement in Cambodia. Smart was the first network to introduce 4G LTE in 2014, 4G LTE Advanced (also known as 4G+) in 2016, and 4G LTE Advanced Pro (also known as 4.5G) with HD Voice (VoLTE) in 2017. In mid-2019, Smart hosted the first 5G live showcase, manifesting its data leadership position in Cambodia. Smart also provides 2G, 2.5G, 3G and 3.75G mobile services, as well as international roaming across more than 190 countries. Its extensive nationwide network coverage stretches to 99% of the Cambodian population.

The company is also rapidly transforming itself into a digital lifestyle brand, having introduced many innovative offerings and lifestyle entertainment value propositions. This includes various international brand partnerships with Universal Music, Apple and Facebook, as well as digital services including Smart Insurance, SmartPay, Pleng by Smart, Pi Pay and SmartNas. Smart aspires to be the #1 and most loved communication tech brand in Cambodia by 2022, while having a strong corporate social responsibility and sustainability agenda for national socio-economic growth.

The company's workforce consists of over 1000 local and foreign experts striving towards a common mission of connecting and making lives better. Live. Life. Be Smart.

**Media Inquiry:**
Smart Axiata
KOAM Tivea
koam.tivea@smart.com.kh

# ធនាគារ ABA និងក្រុមហ៊ុន Smart Axiata ដាក់ឲ្យប្រើប្រាស់ IPification ដែលជាដំណោះស្រាយការចុះឈ្មោះ និងផ្ទៀងផ្ទាត់ដ៏ល្អបំផុតមួយសម្រាប់អ្នកប្រើប្រាស់កម្មវិធី ABA Mobile

**ហុងកុង/រាជធានីភ្នំពេញ 20 តុលា 2021** - **ធនាគារ** ABA **និងក្រុមហ៊ុន** Smart Axiata **បន្តនាំមុខក្នុងវិស័យឌីជីថលូបនីយកម្មរបស់កម្ពុជា ដោយដាក់ឲ្យប្រើប្រាស់នូវដំណោះស្រាយដ៏មានសុវត្ថិភាព និងងាយស្រួលសម្រាប់អតិថិជនក្នុងការកំណត់អត្តសញ្ញាណ និងការការពារអ្នកប្រើប្រាស់៖** IPification **ជាប្រព័ន្ធចុះឈ្មោះ ផ្ទៀងផ្ទាត់ និងការពារការក្លែងបន្លំដ៏រហ័សមួយ។ ធនាគារ** ABA **នឹងដាក់ឲ្យប្រើប្រាស់នូវបច្ចេកវិទ្យា** IPification **ដ៏ល្អបំផុតមួយសម្រាប់អ្នកប្រើប្រាស់របស់ក្រុមហ៊ុន** Smart Axiata **ដែលជាប្រតិបត្តិករទូរគមនាគមន៍ឈានមុខរបស់កម្ពុជា ហើយក្នុងពេលឆាប់ៗនេះ នឹងមានជាមួយប្រតិបត្តិករផ្សេងៗទៀតនៅកម្ពុជាផងដែរ។**

IPification ជាដំណោះស្រាយកំណត់អត្តសញ្ញាណកម្មតាមទូរស័ព្ទដៃដ៏រហ័សមួយដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់អាចផ្ទៀងផ្ទាត់លេខទូរស័ព្ទ ការចុះឈ្មោះ និងការបើកចូលប្រើប្រាស់បានយ៉ាងរហ័ស។ បង្កើតឡើងដោយមានការគិតគូរពីសុវត្ថិភាព បទពិសោធអ្នកប្រើប្រាស់ និងឯកជនភាពទិន្នន័យ ប្រព័ន្ធនេះនឹងអនុញ្ញាតឲ្យធនាគារ ABA អាចពង្រឹងនូវបទពិសោធអ្នកប្រើប្រាស់នៅលើកម្មវិធីសេវាធនាគារតាមទូរស័ព្ទរបស់ខ្លួន ហើយនឹងត្រូវប្រើប្រាស់ជំនួសប្រព័ន្ធលេខសម្ងាត់ប្រើមួយដងៗតាមសារទូរស័ព្ទ (OTP) ដែលកំពុងតែប្រើប្រាស់នៅក្នុងការបើកដំណើរការកម្មវិធីនាពេលបច្ចុប្បន្ននេះ។

ដោយទទួលបានពានរង្វាន់ជាច្រើនសម្រាប់ឧត្តមភាពរបស់ខ្លួនជាងមួយទសវត្សរ៍ចុងក្រោយនេះពីទស្សនាវដ្តីហិរញ្ញវត្ថុ ដូចជា The Banker, Global Finance និង Euromoney ធនាគារ ABA បានក្លាយជាធនាគារពាណិជ្ជកំពូលមួយ និងជាធនាគារឈានមុខផ្នែកសេវាធនាគារឌីជីថលនៅកម្ពុជា ដោយផ្តល់នូវវិសាលគមន៍សេវាដល់បណ្តាអតិថិជនជាច្រើន ដូចជា រូបវន្តបុគ្គល អាជីវកម្មខ្នាតតូច និងសហគ្រាសធុនតូច និងមធ្យម។ ដើម្បីធ្វើឲ្យប្រសើរឡើងបន្ថែមនូវសេវាធនាគារតាមទូរស័ព្ទដ៏ទំនើបរបស់ខ្លួន ធនាគារ ABA ភ្ជាប់ប្រព័ន្ធ IPification សម្រាប់ការចុះឈ្មោះ និងការផ្ទៀងផ្ទាត់អ្នកប្រើប្រាស់ដ៏រលូន។

លោក Askhat Azhikhanov នាយកប្រតិបត្តិធនាគារ ABA មានប្រសាសន៍ថា៖ “យើងមានសេចក្តីរីករាយក្នុងការពង្រីកភាពជាដៃគូយុទ្ធសាស្ត្ររបស់យើងជាមួយក្រុមហ៊ុន Smart Axiata និងក្លាយជាធនាគារដំបូងរបស់កម្ពុជា ដែលដាក់ឲ្យប្រើប្រាស់ប្រព័ន្ធ IPification នៅលើកម្មវិធីសេវាធនាគារតាមទូរស័ព្ទរបស់យើង។ សុវត្ថិភាព និងភាពងាយស្រួលនៃសេវាធនាគារតាមទូរស័ព្ទ ជាអាទិភាពកំពូលរបស់យើង ហើយការដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធ IPification នឹងអនុញ្ញាតឲ្យយើងអាចផ្តល់ជូនអ្នកប្រើប្រាស់កម្មវិធី ABA Mobile

នូវដំណើរការផ្ទៀងផ្ទាត់កាន់តែងាយស្រួលដោយរក្សាសុវត្ថិភាពកម្មវិធីក្នុងពេលជាមួយគ្នាផងដែរ។ ធនាគារ នឹងបន្តនាំការអភិវឌ្ឍចុងក្រោយបង្អស់មកកាន់ទីផ្សារក្នុងស្រុកដោយពន្លឿនបន្ថែមនូវបរិវត្តកម្មឌីជីថលទូទាំងប្រទេស”។

Benefit Vantage Limited ជាក្រុមហ៊ុនបង្កើតប្រព័ន្ធ IPification និងផ្តល់សេវាសកលឈានមុខផ្នែកប្រព័ន្ធផ្ទៀងផ្ទាត់តាម IP ទូរស័ព្ទ។

លោក Stefan Kostic នាយកប្រតិបត្តិប្រព័ន្ធ IPification មានប្រសាសន៍ថា៖ “នេះជាឯកសិទ្ធិពិសេសមួយដែលបានសហការជាមួយក្រុមហ៊ុនឈានមុខផ្នែកឌីជីថលកំពូលទាំងពីរនៅកម្ពុជា គឺធនាគារ ABA ជាធនាគារឈានមុខគេផ្នែកសេវាធនាគារឌីជីថល និងក្រុមហ៊ុន Smart Axiata ជាប្រតិបត្តិករទូរគមនាគមន៍ចល័តឈានមុខគេ។ ធនាគារ ABA ជាគំរូដ៏ល្អបំផុតនៃការផ្តល់អាទិភាពដល់អ្នកប្រើប្រាស់ដោយផ្តល់ជូនអ្នកប្រើប្រាស់នូវប្រព័ន្ធផ្ទៀងផ្ទាត់ដែលមិនប៉ះពាល់ដល់សុវត្ថិភាព បទពិសោធន៍អ្នកប្រើប្រាស់ ឬក៏ឯកជនភាពទិន្នន័យឡើយ”។

អតិថិជនរបស់ក្រុមហ៊ុន Smart Axiata ដែលជាអ្នកប្រើប្រាស់កម្មវិធី ABA Mobile នឹងទទួលបាននូវបទពិសោធប្រព័ន្ធផ្ទៀងផ្ទាត់តាមទូរស័ព្ទដ៏ល្អបំផុត IPification នេះមុនគេសម្រាប់តម្រូវការសេវាធនាគារតាមទូរស័ព្ទរបស់ខ្លួន ចាប់ពីពាក់កណ្តាល់ខែតុលា ឆ្នាំ2021 នេះ។

លោក Thomas Hundt នាយកប្រតិបត្តិក្រុមហ៊ុន Smart Axiata មានប្រសាសន៍ថា៖ “ការដាក់ឲ្យប្រើប្រាស់នូវបច្ចេកវិទ្យា និងដំណោះស្រាយចុងក្រោយគេបង្អស់ដើម្បីផលប្រយោជន៍ទាំងអ្នកប្រើប្រាស់ និងអាជីវកម្ម គឺជាគោលដៅចម្បងរបស់ក្រុមហ៊ុន Smart Axiata ជានិច្ច។ ភាពជាដៃគូរបស់យើងជាមួយក្រុមហ៊ុន Benefit Vantage Limited គឺជាគំរូមួយផ្សេងទៀតនៃតួនាទីដ៏សំខាន់របស់ប្រតិបត្តិករទូរស័ព្ទចល័តក្នុងការអភិវឌ្ឍទិដ្ឋភាពសេដ្ឋកិច្ច និងបច្ចេកវិទ្យានៅព្រះរាជាណាចក្រកម្ពុជា។ យើងមានសេចក្តីសោមនស្សរីករាយដែលដៃគូយុទ្ធសាស្ត្ររបស់យើង គឺធនាគារ ABA ជាធនាគារដំបូងគេដែលផ្តល់នូវដំណោះស្រាយនេះ ហើយយើងរំពឹងថា អាជីវកម្មផ្សេងៗជាច្រើនទៀតនឹងចាត់វិធានការដើម្បីសុវត្ថិភាព និងភាពងាយស្រួលកាន់តែខ្លាំងសម្រាប់អ្នកប្រើប្រាស់របស់ខ្លួន”។

**អំពីប្រព័ន្ធ IPification**

IPification កំពុងកសាងគ្រឹះសម្រាប់ការផ្ទៀងផ្ទាត់តាមទូរស័ព្ទនាពេលបច្ចុប្បន្ន និងអនាគត។ ដោយផ្ទៀងផ្ទាត់នូវឧបករណ៍ ស៊ីម និងលេខទូរស័ព្ទ តាមរយៈអាសយដ្ឋាន IP បច្ចេកវិទ្យាប្រព័ន្ធ IPification អនុញ្ញាតឲ្យមានការអនុម័តលើប្រតិបត្តិការ ការចុះឈ្មោះ ការផ្ទៀងផ្ទាត់អ្នកប្រើប្រាស់ទូរស័ព្ទដ៏សុវត្ថិភាពមិនបាច់ប្រើនិងចុចពាក្យសម្ងាត់ និងប្រព័ន្ធការពារការក្លែងបន្លំសម្រាប់ការប្រើប្រាស់ទូរស័ព្ទចល័តណាមួយ។ ដោយមានប្រើប្រាស់ស្រាប់នៅក្នុងប្រទេស និងតំបន់ជាច្រើន ប្រព័ន្ធ IPification ទទួលបានទំនុកចិត្តពីក្រុមហ៊ុនទូរគមនាគមន៍ បច្ចេកវិទ្យា ទូទាត់ និងផ្ទេរប្រាក់ រួមមាន ក្រុមហ៊ុន Microsoft, GBG, DataZoo, 3HongKong, Axiata Digital។

ក្រុមហ៊ុន Benefit Vantage Limited ជាក្រុមហ៊ុនផ្តល់សេវាសន្តិសុខ និងការពារទិន្នន័យនៅអាស៊ីដែលមានទីស្នាក់ការកណ្តាលនៅហុងកុង។ ក្រុមហ៊ុននេះមានឧបសម្ព័ន្ធនៅប្រទេសស្វីស IPIFICATION INTERNATIONAL AG និងក្រុមហ៊ុនតំណាងដែលធ្វើប្រតិបត្តិការនៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស ស៊ែប៊ី រុស្ស៊ី បូស្នៀ ប្រេស៊ីល ឥណ្ឌា វៀតណាម និងប៉ាគីស្ថាន។
សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅវិបសាយ៖ www.ipification.com

**ទំនាក់ទំនងសួរព័ត៌មាន៖**
IPification
Alexandra Kalinina
alexandra.kalinina@ipification.com

## **អំពីធនាគារ ABA**

ធនាគារ ABA គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឯកជនឈានមុខមួយរបស់កម្ពុជា។ ជាមួយសាខា 79 ម៉ាស៊ីនស្វ័យសេវាជាង 600 ទូទាំងប្រទេស និងសេវាធនាគារអនឡាញដ៏ទំនើប ធនាគារ ABA ផ្តល់សេវាហិរញ្ញវត្ថុដ៏ទំនើបដ៏ច្រើនជូនអតិថិជនជាច្រើននាក់។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វិបសាយ៖ www.ababank.com។

ធនាគារ ABA គឺជាបុត្រសម្ព័ន្ធរបស់ធនាគារជាតិកាណាដា ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុ មានទ្រព្យសកម្មជាង 274 ប៊ីលានដុល្លារ គិតត្រឹមថ្ងៃទី 30 ខែមេសា 2021។ ដោយមានស្នាក់ការកណ្តាលស្ថិតនៅទីក្រុងម៉ុងរ៉េអាល់ ធនាគារជាតិកាណាដាបានពង្រីកសាខានៅស្ទើរតែគ្រប់ខេត្ត នៃប្រទេសជាមួយនឹងអតិថិជនក្នុងដៃ 2.7 លាននាក់។ ជាគ្រឹះស្ថានហិរញ្ញវត្ថុធំជាងគេលំដាប់ទី 6 ក្នុងប្រទេសកាណាដា និងនាំមុខគេនៅកេបិច ធនាគារជាតិកាណាដា ជាជម្រើសនៃបណ្តាសហគ្រាសធុនតូច និងមធ្យមនានានៅទីនោះ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វិបសាយ៖ www.nbc.ca។

**ទំនាក់ទំនងសួរព័ត៌មាន៖**
**ធនាគារ** ABA
ចាន់ ជីវ៉ា
Chan.Chiva@ababank.com

## **អំពីក្រុមហ៊ុន Smart**

ក្រុមហ៊ុន Smart Axiata Co., Ltd. ជាប្រតិបត្តិករទូរគមនាគមន៍ចល័តឈានមុនគេក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្នក្រុមហ៊ុនបាននិងកំពុងបម្រើអតិថិជនចំនួន ៧.៥ លាននាក់ ស្ថិតក្រោមស្លាកសញ្ញា “Smart”។ Smart Axiata គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមេ មានឈ្មោះថា “Axiata Group Berhad” ដែលជាក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ធំជាងគេបង្អស់មួយក្នុងទ្វីបអាស៊ី។

ក្រុមហ៊ុន Smart គឺជាប្រតិបត្តិករទូរគមនាគមន៍ចល័តដែលមានភាពឈានមុខគេបង្អស់ផ្នែកសេវាបច្ចេកវិទ្យាទំនើបទាន់សម័យក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុន Smart គឺជាប្រតិបត្តិករដំបូងបង្អស់ដែលបានដាក់ឱ្យដំណើរការសេវាបច្ចេកវិទ្យាជំនាន់ទី៤ “4G LTE” ក្នុងឆ្នាំ២០១៤ បច្ចេកវិទ្យា 4G+ ក្នុងឆ្នាំ២០១៦ បច្ចេកវិទ្យា 4G+ ជាមួយ HD Voice (VoLTE) និង 4G LTE Advance Pro ក្នុងឆ្នាំ២០១៧។ នៅពាក់កណ្តាលឆ្នាំ២០១៩ Smart បានរៀបចំកម្មវិធីបង្ហាញសាកល្បងបច្ចេកវិទ្យាជំនាន់ទី៥ “5G” ដំបូងគេបង្អស់នៅកម្ពុជាដោយបង្ហាញពីភាពជាអ្នកដឹកនាំផ្នែកសេវាទិន្នន័យចល័ត។ ក្រុមហ៊ុន Smart ក៏មានផ្តល់នូវបច្ចេកវិទ្យាទូរស័ព្ទចល័តដ៏សម្បូរបែបរួមមាន៖ សេវាបច្ចេកវិទ្យា 2G, 2.5G, 3G និង3.75G ក៏ដូចជាសេវាកម្មទូរស័ព្ទក្រៅប្រទេស (Roaming) ដែលអាចប្រើបានច្រើនជាង ១៩០ប្រទេស។ Smart បាននិងកំពុងផ្តល់សេវាគ្របដណ្តប់ក្នុងតំបន់ប្រជាសាស្ត្រច្រើនជាង ៩៩% (កៅសិបប្រាំបួន) ភាគរយ នៅទូរទាំងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនក៏កំពុងបម្លែងខ្លួនយ៉ាងសកម្មទៅជាប្រតិបត្តិករបែបឌីជីថល តាមរយៈការផ្តល់នូវសេវាកម្ម និងកម្មវិធីកម្សាន្តលក្ខណៈស៊ីវិល័យប្រកបដោយភាពច្នៃប្រឌិតជាច្រើន។ នេះរួមបញ្ចូលភាពជាដៃគូជា

មួយភាគីអន្តរជាតិនានាដូចជា៖ ក្រុមហ៊ុន Universal Music ក្រុមហ៊ុន Apple និង ក្រុមហ៊ុន Facebook ក៏ដូចជាសេវាកម្មឌីជីថលនានា រួមមាន៖ សេវាធានារ៉ាប់រងជីវិតឆ្លាតវៃ សេវា SmartPay សេវា Pleng by Smart សេវា Pi Pay និងសេវា SmartNas។ ក្រុមហ៊ុន Smart មានចក្ខុវិស័យក្លាយជាក្រុមហ៊ុនលេខ១ និងជាក្រុមហ៊ុនបច្ចេកវិទ្យាទូរគមនាគមន៍ដែលទទួលបានក្តីស្រលាញ់ពេញចិត្តបំផុតនៅព្រះរាជាណាចក្រកម្ពុជានៅត្រឹមឆ្នាំ២០២២ តាមរយៈកម្មវិធីទំនួលខុសត្រូវខ្ពស់លើកិច្ចការងារសង្គម និងកម្មវិធីនិរន្តរភាពនានាសម្រាប់កំណើនសេដ្ឋកិច្ច និងសង្គមជាតិ។

ក្រុមហ៊ុន Smart មានបុគ្គលិកនិយោជិតសរុបប្រមាណជាង ១.០០០ (មួយពាន់) នាក់ ក្នុងនោះរួមបញ្ចូលទាំងនិយោជិតក្នុងស្រុក និងនិយោជិតបរទេសដែលកំពុងខិតខំប្រឹងប្រែងឆ្ពោះទៅសម្រេចបេសកកម្មរួមគ្នាក្នុងការផ្សារភ្ជាប់ និងធ្វើឱ្យជីវិតកាន់តែប្រសើរឡើង។ Smart ជីវិតរស់រវើក!

**ទំនាក់ទំនងសួរព័ត៌មាន៖**

ក្រុមហ៊ុន Smart Axiata
គាំ ទីវា
koam.tivea@smart.com.kh